**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:១០២
ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៥
**សាលដីកា**
លេខ:១៤៨
ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៦

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៦ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ......... ជាប្រធាន
២-លោក ........... ជាចៅក្រម
៣-លោក ........... ជាចៅក្រម
៤-លោក ............ ជាចៅក្រម
៥-លោក .............. ជាចៅក្រម

**ក្រឡាបញ្ជី**

-លោក .............

**តំណាងមហាអយ្យការ**

-លោក ................ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ១៤៤(ឈ) ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៤ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៤៤៧ ចុះថ្ងៃទី០២ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះសយ(ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទស្រីអាយុ៤៣ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ដូរ មានទីលំនៅ ផ្ទះលេខ១៤២ ផ្លូវលេខ១៣៨ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះអ៊ឹង សារិ(ស) ម្តាយឈ្មោះរស់ អឿន (ស) ។

មានមេធាវីលោក ........... ។

និងចុងចម្លើយឈ្មោះអសរ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុសអាយុ៤៣ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់-ដូរ មានទីលំនៅភូមិផ្សារសាមគ្គី ឃុំកណ្តាលជុំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះអ៊ុង ហ៊ាន (ស)ម្តាយឈ្មោះញ៉ែម ផុន(ស) ។

មានមេធាវីលោក...........។

**កម្មវត្ថុបណ្តឹង:** ប្តឹងទាមទារដីលំនៅដ្ឋាន និងផ្ទះតាមកិច្ចសន្យា, ទាមទារថ្លៃឈ្នួលផ្ទះ និងសុំឱ្យរុះរើឥវ៉ាន់ចេញពីផ្ទះ ។

បានឃើញបណ្ដឹងសាទុក្ខលេខ៧៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ឈ្មោះសយ និង បណ្ដឹងសាទុក្ខលេខ៣៥២ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ របស់ឈ្មោះអសរ និងអ្នកស្រីទិត ស៊ីណាត បានប្ដឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១០២ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៥ របស់តុលាការកំពូល តាមពាក្យបណ្ដឹងចុះថ្ងៃទី០៦-១១-២០០៣ របស់ដើមចោទឈ្មោះសយ ថាៈ ខ្លួនប្ដឹងសុំគ្រប់គ្រងដី និងផ្ទះតាមកិច្ចសន្យាទិញ-លក់ដី និងផ្ទះពីឈ្មោះអសរ និងប្រពន្ធឈ្មោះទិត្យ ស៊ីណា ដោយហេតុថា កាលពីថ្ងៃទី០៤-០៣-២០០២ ពីរនាក់ប្ដីប្រពន្ធនេះបានលក់ដី និងផ្ទះមកឱ្យខ្លួនហើយឈ្មោះទាំងពីរនាក់ប្ដីប្រពន្ធនេះ ធ្វើកិច្ចសន្យាជួលផ្ទះរបស់ខ្លួនវិញ ហើយអ្នកទាំងពីរនេះមិនគោរពតាមកិច្ចសន្យានេះឡើយ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១៣ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៤ របស់តុលាការខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្ដឹងរបស់ដើមចោទ ចុះថ្ងៃទី០៦-១១-២០០៣ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ឱ្យឈ្មោះអសរ និងប្រពន្ធឈ្មោះទិត ស៊ីណាត ជញ្ជូនទ្រព្យសម្បត្តិរបស់ខ្លួនចេញពីផ្ទះកើតហេតុនេះ ហើយប្រគល់ផ្ទះ និងដីឡូតិ៍នៅភូមិផ្សារសាមគ្គី ឃុំកណ្ដាលដុំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ ឱ្យទៅឈ្មោះសយ ដើមចោទចាប់តាំងពីថ្ងៃនេះតទៅ តាមមាត្រា៣៨នៃច្បាប់ស្ដីពីកិច្ចសន្យា និង ការទទួលសុខត្រូវក្រៅតិច្ចសន្យាដែលប្រកាសឱ្យប្រើតាមព្រឹត្យលេខៈ៣៨ ក្រច ចុះថ្ងៃទី២៨-១០-១៩៨៨

៣- បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្ដីចំនួន៧.០០០៛ ក្នុងនោះមានពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹងចំនួន១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន២០០៛ និងចំណាយលើអាជ្ញាធរកណ្ដាលចំនួន ៥.០០០៛ សរុបទាំងអស់៧.០០០៛ និងពន្ធសមាមាត្រ១% ។

សាលក្រមនេះជំនុំជំរះ ជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ និងបើកផ្លូវឱ្យប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់ចុះថ្ងៃទី២៩-០៣-២០០៤ របស់ឈ្មោះអសរ បានប្ដឹងមិនសុខចិត្តនឹងសលក្រម របស់តុលាការខេត្តកំពង់ស្ពឺត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៣៣ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៤ របស់តុលាការខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១- ទទួលពាក្យបណ្ដឹងទាស់របស់ឈ្មោះអសរ ចុះថ្ងៃទី២៩-០៣-២០០៤ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ១៣ ចុះថ្ងៃទី០៤-០៣-២០០៤ របស់តុលាការខេត្តកំពង់ស្ពឺ ត្រង់ចំណុចទី២ នៃសាលក្រមចោលជាអសារបង់ ។

៣- បង្គាប់ឱ្យដើមបណ្តឹងទាស់ឈ្មោះអសរ និងប្រពន្ធឈ្មោះទិត្យ ស៊ីណា សងប្រាក់ដើមចំនួន ៣៦០០ដុល្លារ(បីពាន់ប្រាំមួយរយដូល្លារអាមេរិក)បន្ថែមលើប្រាក់ដែលឈ្មោះសយ បានទទួលចំនួន ៦.៥០០ដុល្លារ (ប្រាំមួយពាន់ប្រាំរយដូល្លារអាមេរិក) រួចហើយ និងឱ្យបង់ប្រាក់ការប្រាក់ចំនួន៦០០ ដុល្លារ (ប្រាំមួយរយដុល្លារអាមេរិក) សរុប៤២០០ដុល្លារ (បួនពាន់ពីរយដុល្លារអរិក) ឱ្យទៅចុងចម្លើយឈ្មោះសយ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។ យោងតាមមាត្រា៥៦,៥៧ នៃច្បាប់ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិចសន្យា បើឈ្មោះអសរ និងប្រពន្ធឈ្មោះទិត ស៊ីណាត ពុំមានប្រាក់សងគ្រាប់ចំនួនទេនោះ ត្រូវរឹបអូសផ្ទះ និងដីឡូត៍ដែលមានទំនាស់នោះ លក់ឡាយឡុងដើម្បីជានាសំណងគ្រប់ចំនួនឱ្យទៅចុងចម្លើយឈ្មោះសយ ក្នុងករណីរឹងរូសពុំព្រមសងត្រូវចាប់ដាក់គុកបង្ខំរូបរាងកាយក្នុងរឿងរដ្ឋប្បវេណី ។

៤- បង្គាប់ឱ្យឈ្មោះអសរ បង់ប្រាក់ប្រដាប់ក្តីចំនួន៧.០០០៛ ក្នុងនោះមានប្រាក់ពន្ធហ្នឹង ប្រាក់ចុះបញ្ជីក្តីចំនួន១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ អ្នករត់ដីកាកោះ៥០០០៛ សរុប៧០០០៛ ដែលឈ្មោះសយ បានបង់រួចហើយ និងឱ្យចង់ពន្ធសមាមាត្រ១% នៃប្រាក់ជំពាក់ទាំងមូលពេលសាលក្រមនេះចូលជាស្ថាពរ ។

៥- សាលក្រមនេះជំនុំជំរះ ជាសាធារណៈ ចំពោះមុខគួភាគី បើភាគីណាមិនសុខចិត្តនឹងសេចក្តីសម្រេចនេះ បើកផ្លូវឲ្យប្តឹងឧទ្ធរណ៍រយៈពេល២ខែតាមច្បាប់កំណត់ ។

បានឃើញ បណ្តឹងឧទ្ធរណ៍លេខ១៥ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះសយ បានប្តឹង មិនសុខចិត្តនឹងសាលក្រមរបស់តុលាការខេត្តកំពង់ស្ពឺត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៤៤(ឈ) ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៤-០៥-២០០៤ របស់ឈ្មោះសយ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិចច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ៣៣ ចុះថ្ងៃទី២៤-០៥-២០០៤ និងសាលក្រមរដ្ឋប្បវេណីកំបាំងមុខលេខ១៣ ចុះថ្ងៃទី០៤-០៣-២០០៤ របស់តុលាការខេត្តកំពង់ស្ពឺចោលជាអសារបង់ ។

៣-បង្គាប់ឱ្យឈ្មោះអសរ និងប្រពន្ធឈ្មោះទិត ស៊ីណាត សងប្រាក់ដើមចំនួន៧០០០ដុល្លារអាមេរិក(ប្រាំពីរពាន់ដុល្លារអាមេរិក) ការប្រាក់៥% ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃទី០៤-០៩-២០០៤ រហូតដល់ថ្ងៃទូទាត់បំណុលរួច និងជម្ងឺចិត្តចំនួន៥០០០ដុល្លារអាមេរិក(ប្រាំពាន់ដុល្លាអាមេរិក)ឱ្យទៅដើមចោទឈ្មោះសយចាប់ពីពេលដែលសាលដីកានេះចូលជាស្ថាពរ។សំណួមពរលើសពីនេះបដិសេធចោល។

-បើគ្មានប្រាក់សងទេត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុងជានាសំណង

-បើរឹងរូសត្រូវដាក់គុកចង្ខំរូបកាយតាមច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

៤-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់ទុករួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០៛ ចំណាយលើការប្រគល់ដីកាកោះចំនួន៥.០០០៛ និងអាជ្ញាធរតុលាការចំនួន៥.០០០៛ ។ នៅពេលសាលដីកានេះចូលជាស្ថាពរបង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន១៣.០០០៛ ទៅឱ្យដើមចោទវិញ និងបង្គាប់ឱ្យចុងចម្លើយបង់ ពន្ធសមាមា ត្រ១% លើប្រាក់ដើម ការប្រាក់ និងជម្ងឺចិត្ត ។

៥- សាលដីកានេះជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី៣១-០៨-២០០៤ ចំពោះមុខគូក្តី និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨-០៩-២០០៤ កំបាំងមុខគូក្តីតែចាត់ទុកជាចំពោះមុខបើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់

បានឃើញបណ្តឹងសាទុក្ខលេខៈ៣៥២ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ របស់ឈ្មោះអសរ និងប្រពន្ធឈ្មោះទិត ស៊ីណាត បានប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូលនិងបណ្តឹងសាទុក្ខលេខ៧៣ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ឈ្មោះសយ បានប្តឹងមិនសុខចិត្ត នឹងសាលដីការបស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី៣នៃសាលដីការបស់សាលាឧទ្ធរណ៍ ។

បានឃើញសារណាការពាររបស់ឈ្មោះអសរ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៥ ។

បានឃើញសារណារឆ្លើយតបរបស់ឈ្មោះសយ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៥ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា

បណ្តឹងសាទុក្ខរបស់លោកអសរ និងបណ្តឹងសាទុក្ខរបស់អ្នកស្រីសយ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិចារណា ។

សាលាឧទ្ធរណ៍សម្រេចសេចក្តីមកនេះត្រឹមត្រូវហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ ។

ក្រឡាបញ្ជីអានសារណារបស់ឈ្មោះសយ ។

អ្នកស្រីទិត ស៊ីណាត ប្រពន្ធឈ្មោះអសរ បានឆ្លើយថា ព្រោះសាលាឧទ្ធរណ៍បានសម្រេចដោយអយុត្តិធម៌ ដោយខ្លួនបានបង់ការប្រាក់ខុសច្បាប់ ឱ្យគាត់បានច្រើនណាស់ហើយដែរនេះគឺជារឿងខ្ចីលុយចងការប្រាក់ទេ មិនមែនជាការទិញលក់ផ្ទះទេ ខ្លួនបានទៅខ្ចីប្រាក់គាត់ចំនួន មួយម៉ឺនដុល្លាអាមេរិក តែអ្នកស្រីសយ បានឱ្យខ្លួនជាពីរ ដំណាក់កាលដោយសរុបទាំងពីរលើកនេះខ្លួនបានទទួលប្រាក់តែ ប្រាំបីពាន់បួនរយដុល្លារអាមេរិក ប៉ុណ្ណោះ ចំពោះប្រាក់ចំនួន មួយពាន់ប្រាំមួយរយ នៅគាត់ដកថ្លៃទឹកតែ ដូច្នេះសរុបប្រាក់ទាំងអស់មានទំនួនតែមួយ ម៉ឺនមួយរយ ប៉ុណ្ណោះ ។

ការប្រគល់លុយនេះ គឺគាត់បានកត់លេខលុយត្រឹមត្រូវណាស់ ដោយមានឯកសារនៅក្នុងសំណុំរឿងស្រាប់។

**សំណូមពរៈ** សុំកាត់យកការប្រាក់ខុសច្បាប់មកបញ្ចូលជាប្រាក់ដើមវិញ ហើយសុំបដិសេធសាលដីកា របស់សាលាឧទ្ធរណ៍ចោលទាំងមូល ។

មេធាវីលោក...........ការពារឱ្យលោកអសរ បានធ្វើសេចក្តីសន្និដ្ឋានថា

កាលពីនៅតុលាការខេត្តអ្នកស្រីសយ បានប្តឹងទាមទារសុំសិទ្ធិគ្រប់គ្រងលើដី និងសុំឱ្យកូនក្តីរបស់ខ្លួនចេញពីផ្ទះ ការសម្រេចរបស់តុលាការខេត្ត ក៏បានសម្រេចតាមបណ្តឹងរបស់ដើមចោទដោយឱ្យកូនក្តីរបស់ខ្លួនចុះចេញពីផ្ទះដែលមានភាពអយុត្តិធម៌ណាស់ ទើបកូនក្តីរបស់ខ្លួនប្តឹងឧទ្ធរណ៍សាលក្រមរបស់តុលាការខេត្តមិនទាន់ចូលជាស្ថាពរ គាត់ក៏នាំគ្នាទៅដេញអ្នកស្រីទិត ស៊ីណាត និងគ្រួសាររបស់កូនក្តីខ្លួនឱ្យចុះចេញ ដែលត្រង់នេះល្មើសនឹងមាត្រា១៥៧ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

កាលពីនៅសាលាឧទ្ធរណ៍ពេលសវនាការដើមចោទមិនបានចូលរួមសវនាការទេ សាលាឧទ្ធរណ៍បង្វែបណ្តឹងមកជាកិច្ចសន្យាខ្ចីប្រាក់ទៅវិញដែលការសម្រេចនេះមិនទាន់មានពាក្យបណ្តឹងទេ ដូច្នេះសាលាឧទ្ធរណ៍បានសម្រេចខុសពីកម្មវត្ថុបណ្តឹងហើយ។ សូមឯកឧត្តមមេត្តាសម្រេចលើចំណុចនេះឱ្យបានច្បាស់ ។

ការលក់ផ្ទះគ្មានបានដាក់តម្លៃពិតប្រាកដទេ ដែលមានឯកសារនៅក្នុងសំណុំរឿងស្រាប់ ដូច្នេះនេះបញ្ជាក់ឱ្យ ឃើញថាអ្នកស្រីសយ មិនអាចក្លាយជាម្ចាស់កម្មសិទ្ធិបានឡើយហើយផ្ទុយនឹងមាត្រា ១៧៧ នៃច្បាប់ភូមិបាល ។

**សំណូមពរ** សុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោលទាំងមូល ហើយសុំបង្វិលសំណុំរឿងនេះទៅ សាលាឧទ្ធរណ៍ ដើម្បីឱ្យសាលាឧទ្ធរណ៍សម្រេចជាថ្មីឡើងវិញ ។

មេធាវីលោក........... ការពារឱ្យអ្នកស្រីសយ បានធ្វើសេចក្តីសន្និដ្ឋានថា

ជាដំបូងខ្លួនសុំអនុញ្ញាតឯកឧត្តម សួរទៅអ្នកស្រីទិត ស៊ីណាត ថា តើអ្នកស្រីបានអះអាងថាបានបង់ការ ប្រាក់មួយខែ៥០០ និង ៦០០ មានហេតុផល ឬ ភស្តុតាងមកបញ្ជាក់ដែរឬទេ ?

តាមពាក្យបណ្តឹងនៅតុលាការថ្នាក់ក្រោមកូនក្តីរបស់ខ្លួនបានដាក់ប្តឹងទាមទារផ្ទះ និង ដីពិតមែន តែក្រោយមក ក៏បានដាក់បណ្តឹងប្តឹងទាមទារប្រាក់វិញ ហើយក៏សាលាឧទ្ធរណ៍បានសម្រេចតែលើបណ្តឹងទាមទារប្រាក់តែប៉ុណ្ណោះ ដូច្នេះមេធាវីចុងចម្លើយបានសន្និដ្ឋានផ្ទុយពីសេចក្តីសម្រេចហើយ ។

តាមពិតកិច្ចសន្យាទិញ-លក់ គឺ ជាកិច្ចសន្យាមួយការពារទៅថ្ងៃក្រោយក្នុងករណីដែលគាត់ប្រកែក ឬ គ្មាន ប្រាក់សងវិញតែប៉ុណ្ណោះ ។ អ្នកស្រីសយ បានទទួលការប្រាក់ ប្រាំរយក្នុងមួយខែ មែនដោយសរុបប្រាក់ទាំងអស់បាន ប្រាំមួយពាន់ប្រាំរយដូល្លារអាមេរិក តែការប្រាក់នេះគាត់ក៏មិនបានធ្វើលិខិតស្នាមអ្វីដែរនេះបញ្ជាក់ពីភាពស្មោះត្រង់របស់គាត់ហើយ ដោយគាត់បានទទួលស្គាល់ ដោយបានកាត់ការប្រាក់នេះទៀត ឃើញថា ប្រាក់ដើមនៅសល់តែ ប្រាំពាន់ប្រាំរយ តែប៉ុណ្ណោះ ។

តាងនាមខ្លួនជាមេធាវី ហើយជាអ្នកតំណាងឱ្យអ្នកស្រីសយ ខ្លួនសុំសំណូមពរដូចខាងក្រោម៖ សុំកែប្រែដោយកាត់បន្ថយប្រាក់ពី ប្រាំពីរពាន់ដុល្លា មកនៅតែ ប្រាំពាន់វិញ និងសំណងជម្ងឺចិត្តមាន ប្រាំពាន់ដុល្លា មកត្រឹមតែ បីពាន់ដុល្លាវិញ ដើម្បីបញ្ចប់រឿងក្តីត្រឹមនេះ ជៀសវាងការអូសបន្ទាយពេលវេលា ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអាយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ចុងចម្លើយ សារណារបស់ដើមចោទ និងសេចក្តីសន្និដ្ឋានរបស់មេធាវីគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

យល់ឃើញថា៖ បណ្តឹងសាទុក្ខលេខ៣៥២ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ របស់លោក អសរ និងអ្នកស្រីទិត ស៊ីណាត ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមក ជំនុំជំរះ បាន ដោយតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

យល់ឃើញថា៖ ការដែលសាលាឧទ្ធរណ៍សម្រេចឱ្យចុងចម្លើយសងប្រាក់ដើមទៅដើមចោទចំនួន ៧.០០០ដុល្លារអាមេរិក ដោយសំអាងចុងចម្លើយបានខ្ចីប្រាក់ចំនួន១២.០០០ដុល្លារ ហើយចុងចម្លើយ បានឱ្យការប្រាក់ខុសច្បាប់ចំនួន៥.០០០ដុល្លារ ហើយនោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា តាមលិខិតទទួលប្រាក់ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០២ និងលិខិតទទួលប្រាក់ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០២ ចំនួនប្រាក់ដែលដើមចោទប្រគល់ឱ្យចុងចម្លើយមានត្រឹមតែ៨២ សន្លឹកស្មើនឹងចំនួន៨២០០ដុល្លារអាមេរិក ដូចការអះអាងរបស់ចុងចម្លើយដែរ ។

យល់ឃើញថា៖ ការដែលមេធាវីដើមចោទ សុំឱ្យតុលាការកំពូល បន្ថយប្រាក់សំណង និងជម្ងឺចិត្តឱ្យ ដើមចោទនោះ តុលាការកំពូល ដែលជំនុំជំរះអង្គច្បាប់ពុំអាចពិចារណាបានទេ ។

យល់ឃើញថា ដើមចោទបានធ្វើសារណាជូនមក តុលាការកំពូល រួចហើយ ប៉ុន្តែអ្នកស្រីពុំបានចូលរួម នាពេលសវនាការនេះទេ ឯមេធាវីអ្នកស្រីបានចូលរួម ដូចនេះ តុលាការកំពូលជំនុំជំរះ តំបាំងមុខអ្នកស្រី ចាត់ទុកជាចំពោះមុខ ។

យល់ឃើញថា: សាលដីការដ្ឋប្បវេណីលេខ១៤៤(ឈ) ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទម្រង់ទាំង គតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី ចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១- ទទួលបណ្តឹងសាទុក្ខលេខ៣៥២ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៤ របស់ចុងចម្លើយទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ១៤៤(ឈ) ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១០២ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៥ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤ -រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ ដែលដើមចោទ បានបង់ជួសនៅតុលាការកំពូល គឺៈ

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩០០០៛ ។

៥- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៦ ។